ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**CDRI—Cambodia's leading independent development policy research institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

**វិច្ឆិកា ២០១០** / November 2010

**ស្រ៊ី បុប្ផារ័ត្ន / Sry Bopharath**

**សាំង ច័ន្ទហាង / Saing Chan Hang**

**ប៉ុន ដូរីណា / Pon Dorina**

បកប្រែដោយ៖ **យូ សិទ្ធីរិទ្ធ និង ខេង សេង**

## ភ្នំពេញ កម្ពុជា

## Phnom Penh, Cambodia

**TO SUBSCRIBE, PLEASE CONTACT:**

*Office address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia; *postal address:* CDRI, PO Box 622 Phnom Penh, Cambodia; *tel:* (855-23) 881-384/881-701/881-916/883-603 ; *fax:* (855-23) 880-734 ; *email:* pubs@cdri.forum.org.kh; *website:* http://www.cdri.org.kh

## ការបកស្រាយតារាងសំខាន់ៗ

របាយការណ៍នេះ បកស្រាយពីនិន្នាការនៃសូចនាករសេដ្ឋកិច្ចសំខាន់ៗ មួយចំនួនរបស់កម្ពុជា និងប្រទេសជាដៃគូ ដោយធ្វើការប្រៀបធៀប តួលេខនៃខែមុនៗ ជាមួយនឹងខែដូចគ្នា ក្នុងឆ្នាំ២០០៩ ។

នៅខែកញ្ញា ចំនួនភ្ញៀវមកដល់កម្ពុជា ធ្លាក់ចុះ ១៦% ធៀបនឹងខែមុន មកត្រឹម ១៧៣.១១២នាក់ ។ ភ្ញៀវមកសម្រាកលំហែ ធ្លាក់ចុះ ១៦,៧% មកត្រឹម ១៥៣.២៤៣នាក់ ។ ភ្ញៀវមកធ្វើជំនួញ ធ្លាក់ចុះ ១១,៦% មកត្រឹម ១០.២៨១នាក់ និង ភ្ញៀវមកដល់ផ្សេងៗទៀត ធ្លាក់ចុះ ១២% មកត្រឹម ៩៥៨៨នាក់ ។ ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន ភ្ញៀវមកសម្រាកលំហែ កើន ១៥% និង ភ្ញៀវមកដល់ផ្សេងៗទៀត កើន ២០៧% ប៉ុន្តែ ភ្ញៀវមកធ្វើជំនួញ រួមចុះ ១៣,៥% ។

នៅខែកក្កដា អនុមតិគម្រោងសាងសង់សរុប ធ្លាក់ចុះ ៧២% ធៀបនឹងខែមុន មកត្រឹម ៣២,៥លានដុល្លារ ។ អនុមតិគម្រោងសាងសង់ផ្ទះល្វែង ធ្លាក់ចុះ ៩៦% ពី ៩០,៧លានដុល្លារ មកត្រឹម ៣,៥លានដុល្លារ ប៉ុន្តែ អនុមតិគម្រោងសាងសង់ភូមិគ្រឹះ និងផ្ទះ កើន ១៦៤% មកដល់ ៣,០លានដុល្លារ ។ អនុមតិគម្រោងសាងសង់ផ្សេងៗ កើន ៤,០% មកដល់ ២៥,៩លានដុល្លារ ។

នៅខែតុលា ម៉ាស៊ូតឡើងថ្លៃ ២,១% មកដល់ ៤០៤០,៦រៀល/លីត្រ និង សាំងឡើងថ្លៃ ២,០% មកដល់ ៤៤៩៤,៥រៀល/លីត្រ ។ នៅខែដដែល ប្រាក់រៀលឡើងថ្លៃ ០,៧% ទល់នឹងប្រាក់ដុល្លារអាមេរិក ។ ទល់នឹងប្រាក់រៀល ប្រាក់បាតថៃធ្លាក់ថ្លៃ ២,១% ប៉ុន្តែប្រាក់ដុងវៀតណាម ឡើងថ្លៃ ០,៦% ។

នៅខែសីហា ការនាំចូលស៊ីម៉ង់ត៍ ធ្លាក់ចុះ ១៨% មកត្រឹម ១៤,២លានដុល្លារ ប៉ុន្តែការនាំចូលដែកថែប កើន ៣៩% មកដល់ ៤,៥លានដុល្លារ ហើយការនាំចូលបរិក្ខារសំណង់ កើន ៧,៦% ដល់ ៥,៦លានដុល្លារ ។ នៅខែដដែល ការនាំចេញផលិតផលកាត់ដេរទៅកាន់សហរដ្ឋអាមេរិក ធ្លាក់ចុះ ៤,០% មកត្រឹម ២៩លានដុល្លារ ។ ការនាំចេញស្បែកជើង ធ្លាក់ចុះ ១,៩% មកត្រឹម ១០,៥លានដុល្លារ ប៉ុន្តែការនាំចេញផលិតផលវាយនភណ្ឌ កើន ១,១% មកដល់ ៥,៥លានដុល្លារ ។ ការនាំចូលសាំង ធ្លាក់ចុះ ២៣% មកត្រឹម ៦,០លានដុល្លារ ។ នៅក្នុងខែនេះ ប្រតិបត្តិការថវិការបស់រដ្ឋាភិបាល មានអតិរេកប្រមាណ ១៦,៩ពាន់លានរៀល ដោយសារចំណូលចរន្ត មានចំនួន ៤៦២,៨ពាន់លានរៀល ហើយ ចំណាយចរន្ត មាន ៤៤៥,៩ពាន់លានរៀល ។

នៅខែតុលា អង្ករធ្លាក់ថ្លៃ ១,០% មកត្រឹម ២៥៥០រៀល/គីឡូក្រាម នៅខេត្តបាត់ដំបង និង ធ្លាក់ថ្លៃ ១,៩% មកត្រឹម ២៦៥០រៀល/គីឡូក្រាម នៅខេត្តស្វាយរៀង។ អង្ករឡើងថ្លៃ ២,០% ដល់ ២៦០០រៀល/គីឡូក្រាម នៅខេត្តកំពង់ស្ពឺ ហើយរក្សាថ្លៃថេរ នៅខេត្តកំពង់ចាម កំពត និង សៀមរាប ។ ត្រីធ្លាក់ថ្លៃ ១៦% នៅខេត្តបាត់ដំបង ធ្លាក់ ៦,០% នៅខេត្តកំពត និង ១៣,៣% នៅខេត្តសៀមរាប ប៉ុន្តែឡើងថ្លៃ ១,៩% នៅខេត្តកំពង់ស្ពឺ និងកំពង់ចាម ។ ត្រីរក្សាថ្លៃថេរនៅខេត្តស្វាយរៀង ។ សាច់ជ្រូកធ្លាក់ថ្លៃ ៦,៣% នៅខេត្តសៀមរាប ប៉ុន្តែឡើងថ្លៃ ១២%

## Highlights

This report presents trends in a number of economic indicators of Cambodia and its partners. It compares recent figures with those of previous months and the same month in 2009.

In September, visitor arrivals to Cambodia dropped by 16 percent compared with the preceding month, to 173,112. Holiday arrivals decreased by 16.7 percent to 153,243. Business arrivals dropped by 11.6 percent to 10,281 and other arrivals by 12 percent to 9588. Compared with the same month last year, holiday arrivals increased by 15 percent and other arrivals by 207 percent, while business arrivals contracted by 13.5 percent.

In July, total construction approvals declined by 72 percent from the previous month, to USD32.5m. Flat construction approvals decreased by 96 percent, from USD90.7m to USD3.5m, while villa and house approvals increased by 164 percent to USD3.0m. Other construction approvals grew by 4.0 percent to USD25.9m.

In October, the diesel fuel price rose by 2.1 percent and gasoline by 2.0 percent. Diesel traded at KHR4040.6/ℓ and gasoline at KHR4494.5/ℓ. During the same month, the riel appreciated by 0.7 percent against the US dollar. The Thai baht depreciated by 2.1 percent against the riel and the Vietnamese dong appreciated by 0.6 percent.

In August, cement imports decreased by 18 percent to USD14.2m, while steel imports increased by 39 percent to USD4.5m and construction equipment imports by 7.6 percent to USD5.6m. During the same month, clothing exports to the US dropped 4.0 percent to USD29m. Shoe exports declined by 1.9 percent to USD10.5m, while other textile products went up by 1.1 percent to USD5.5m. Gasoline imports declined by 23 percent to USD6.0m. Government budget operations in this month had a surplus of KHR16.9 bn, from current revenues of KHR462.8 bn and current expenditures of KHR445.9 bn.

In October, the price of rice in Battambang dropped by 1.0 percent to KHR2550/kg, and in Svay Rieng by 1.9 percent to KHR2650/kg. In Kompong Speu, rice rose by 2.0 percent to KHR2600/kg, while in Kompong Cham, Kampot and Siem Reap, the price remained stable. The price of fish in Battambang declined by 16 percent, in Kampot by 6.0 percent and in Siem Reap by 13.3 percent, while in Kompong Speu and in Kompong Cham, fish prices rose by 1.9 percent. The fish price in Svay Rieng was unchanged. The

នៅខេត្តបាត់ដំបង ឡើង ១,៦% នៅខេត្តកំពង់ស្ពឺ ៧,២% នៅខេត្តកំពង់ចាម និង ៦,៧% នៅខេត្តស្វាយរៀង ។

នៅខែកញ្ញា ការនាំចេញអង្ករនៅថៃ កើន ៣២% ដល់ ៤៥២លានដុល្លារ និង ការនាំចេញកៅស៊ូ និងជ័រធម្មជាតិប្រហាក់ប្រហែល កើន ១,០% ដល់ ៦៥២លានដុល្លារ ប៉ុន្តែការនាំចេញគ្រាប់ស្វាយចន្ទីនិងគ្រាប់ផ្លែឈើប្រហាក់ប្រហែល ធ្លាក់ចុះ ២៣% មកត្រឹម ១,២លានដុល្លារ ។ ការនាំចេញអង្ករពីវៀតណាម រួមចុះ ៣៤% មកត្រឹម ១៥១លានដុល្លារ ការនាំចេញគ្រាប់ស្វាយចន្ទី រួមចុះ ១៤,៣% មកត្រឹម ១០៨លានដុល្លារ ប៉ុន្តែការនាំចេញកៅស៊ូ កើន ៦,២% មកដល់ ២៤១លានដុល្លារ ។ នៅទីផ្សារថៃ អង្ករឡើងថ្លៃ ៥,៣% មកដល់ ៥៧៨,៧ដុល្លារ/តោន កៅស៊ូឡើងថ្លៃ ៧,៥% មកដល់ ៣០៦៤ដុល្លារ/តោន និង ពោតនិងផលិតផលធ្វើពីពោត ឡើងថ្លៃ ០,៦% មកដល់ ៣៧៧ដុល្លារ/តោន ។ នៅវៀតណាម អង្ករឡើងថ្លៃ ១៥% មកដល់ ៤២៧ដុល្លារ/តោន កៅស៊ូឡើងថ្លៃ ៣៥% មកដល់ ២៩៣៩ដុល្លារ/តោន និង គ្រាប់ស្វាយចន្ទីឡើងថ្លៃ ៤,៨% មកដល់ ៦០០០ដុល្លារ/តោន ។

នៅខែកញ្ញា ការនាំចេញសរុបនៅជប៉ុន កើន ២៥,៦% ។ ទំនិញកម្មន្តសាល កើន ២៦,៥% គ្រឿងយន្ត កើន ៥២,៧% គ្រឿងយន្តអគ្គិសនី កើន ១៧,២% និង បរិក្ខារដឹកជញ្ជូន កើន ២៧,៩% ។ ក្នុងខែកញ្ញានេះដែរ តម្លៃនៃការនាំចេញរបស់សហរដ្ឋអាមេរិក កើន ០,១% មកដល់ ១៥៤ពាន់លានដុល្លារ និង ការនាំចេញរបស់តំបន់អឺរ៉ូ កើន ០,៨% មកដល់ ១៧១,៧ពាន់លានដុល្លារ ។

នៅខែសីហា ឆ្នាំនេះ តម្លៃនៃការនាំចេញរបស់ម៉ាឡេស៊ី ធ្លាក់ចុះ ៣,០% មកត្រឹម ១៦,៨ពាន់លានដុល្លារ ហើយ ការនាំចូល ធ្លាក់ចុះ ៦,៥% មកត្រឹម ១៤ពាន់លានដុល្លារ ។

នៅខែសីហា អតិផរណានៅសហរដ្ឋអាមេរិក មានកម្រិត ១,១% នៅតំបន់អឺរ៉ូ ១,៦% និង នៅជប៉ុន -០,៩% ។ អតិផរណានៅចិន មានកម្រិត ៣,៥% នៅហុងកុង ៣,០% និង នៅកូរ៉េខាងត្បូង ២,៦% ។ អតិផរណានៅម៉ាឡេស៊ី មានកម្រិត ២,១% និង នៅសិង្ហបុរី និងថៃ ៣,៣% ។

នៅខែតុលា សណ្តែកសៀង ឡើងថ្លៃ ៨,២% ដល់ ៤៤៧,៧ដុល្លារ/តោន ពោតឡើងថ្លៃ ១៦,៦% មកដល់ ២៣១ដុល្លារ/តោន និង កៅស៊ូ ឡើងថ្លៃ ១១,៩% មកដល់ ៣៨៥១ដុល្លារ/តោន ។

pork price in Siem Reap contracted 6.3 percent, while in Battambang it grew by 12 percent, Kompong Speu by 1.6 percent, Kompong Cham 7.2 percent and Svay Rieng 6.7 percent.

In September, Thai rice exports rose by 32 percent to USD452m and natural rubber and similar natural gums by 1.0 percent to USD652m, while cashew and similar nuts declined by 23 percent to USD1.2m. Rice exports from Vietnam contracted by 34 percent to USD151m and cashew nuts by 14.3 percent to USD108m, while rubber exports increased 6.2 percent to USD241m. The price of rice in Thai markets increased by 5.3 percent to USD578.7/tonne, rubber by 7.5 percent to USD3064/tonne and maize and maize products by 0.6 percent to USD377/tonne. In Vietnam, the rice price rose 15 percent to USD427/tonne, rubber 35 percent to USD2939/tonne and cashew nuts 4.8 percent to USD6000/tonne.

In Japan, total exports increased by 25.6 percent in September. Manufactured goods increased by 26.5 percent, machinery by 52.7 percent, electrical machinery by 17.2 percent and transport equipment by 27.9 percent. During the same month, the value of US exports increased by 0.1 percent to USD154 bn and euro zone exports by 0.8 percent to USD171.7 bn.

In August, the value of exports in Malaysia dropped 3.0 percent to USD16.8 bn and imports by 6.5 percent to USD14 bn.

In August, inflation in the US was 1.1 percent, in the euro zone 1.6 percent and in Japan minus 0.9 percent. China's inflation was 3.5 percent, Hong Kong's 3.0 percent and South Korea's 2.6 percent. Inflation in Malaysia was 2.1 percent and in Singapore and Thailand 3.3 percent.

In October, the price of soybeans rose by 8.2 percent to USD447.7/tonne, maize by 16.6 percent to USD231/tonne, and rubber by 11.9 percent to USD3851/tonne.

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ និង ថ្លៃទំនិញនៅកម្ពុជា

# Main Economic Activities and Consumer Prices in Cambodia

## Fixed Asset Investment Approvals by CDC

Garments

2008 Q1–2010 Q2




Including expansion projects.
Source: Council for the Development of Cambodia

## Foreign Visitor Arrivals

July 2009–September 2010




Source: Ministry of Tourism

## Phnom Penh: Value of Construction Approvals

May 2009–July 2010




Source: Municipality of Phnom Penh

## Phnom Penh: Inflation

Consumer Price Index

July 2009–September 2010




Source: National Institute of Statistics

## Phnom Penh: Gasoline & Diesel Prices

August 2009–October 2010




Source: CDRI

## Interest Rates on 12-Month Bank Loans

May 2009–July 2010




Source: *Economic & Monetary Statistics*, NBC

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

### Riels per US Dollar
August 2009–October 2010




Source: National Bank of Cambodia

### Riels per THB & VND
August 2009–October 2010




Source: National Bank of Cambodia

### Monetary Survey (%)
May 2009–July 2010




Source: National Bank of Cambodia

### Domestic Credit (%)
May 2009–Junly 2010




Source: National Bank of Cambodia

### Monetary Operations
May 2009–July 2010




Source: National Bank of Cambodia

### External Development Assistance Disbursement
Energy, Power & Electricity
2000-2009




Source: *Cambodia Aid Effectiveness Report 2009*, CDC

# ពាណិជ្ជកម្មក្រៅប្រទេស និង ការអនុវត្តថវិកាជាតិ
# External Trade and National Budget Operations

**Imports: Construction Materials**
January 2009–August 2010




Source: *Economic & Monetary Statistics,* NBC

**Cambodian Exports to US**
January–August 2010




Source: *Economic & Monetary Statistics,* NBC

**Imports: Gasoline**
January 2010–August 2010




Source: *Economic & Monetary Statistics,* NBC

**Current Budget Operations**
June 2009–August 2010




Source: MEF Bulletin

**Current Budget Revenue**
May 2009–July 2010




Source: MEF web site

**Current Budget Expenditure**
June 2009–August 2010




Source: MEF web site

*Revised data on other services

# ថ្លៃស្បៀងអាហារតាមខេត្តក្នុងប្រទេសកម្ពុជា
# Provincial Food Prices

## Food Prices in Siem Reap Province
August 2009–October 2010




Source: CDRI

## Food Prices in Battambang Province
August 2009–October 2010




Source: CDRI

## Food Prices in Kompong Cham Province
August 2009–October 2010




Source: CDRI

## Food Prices in Kampot Province
August 2009–October 2010




Source: CDRI

## Food Prices in Svay Rieng Province
August 2009–October 2010




Source: CDRI

## Food Prices in Kompong Speu Province
August 2009–October 2010




Source: CDRI

# ថ្លៃទំនិញតាមខេត្តក្នុងប្រទេសកម្ពុជា ៖ តាមមុខទំនិញ
# Provincial Goods Prices in Cambodia

**Cambodia: Rice Prices in Three Provinces**




Source: CDRI

**Cambodia: Rice Prices in Three Provinces**




Source: CDRI

**Cambodia: Fish Prices in Three Provinces**




Source: CDRI

**Cambodia: Fish Prices in Three Provinces**




Source: CDRI

**Cambodia: Pork Prices in Three Provinces**




Source: CDRI

**Cambodia: Pork Prices in Three Provinces**




Source: CDRI

# ថ្លៃទំនិញ ការនាំចេញ និង ចំនួនទេសចរអន្តរជាតិចូលទៅប្រទេសជាដៃគូរបស់កម្ពុជា

# Goods Prices, Exports and International Tourist Arrivals to Partners of Cambodia

## Thailand: Prices of Rubber, Rice and Maize

July 2009-September 2010




Source: Bank of Thailand, *Foreign Trade and Balance of Payments*

## Vietnam: Prices of Rubber, Rice and Cashew Nuts

July 2009-September 2010




Source: General Statistics Office of Vietnam

## Thailand: Exports

July 2009-September 2010




Source: Customs Department of Thailand

## Vietnam: Exports

July 2009-September 2010




Source: General Statistics Office of Vietnam

## Thailand: International Arrivals

2009




Source: Thailand Office of Tourism Development

## Vietnam: International Arrivals

June 2009-August 2010




Source: Estimates by General Statistics Office of Vietnam

# សកម្មភាពសេដ្ឋកិច្ច និង អត្រាអតិផរណានៅបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity and Inflation Rates of Selected Economic Partners of Cambodia

**Year-on-Year Growth of Main Exports: Japan**
July 2009–September 2010




Source: Japanese Trade and Investment Statistics

**Goods Exports: US, Euro Zone & Japan**
July 2009–September 2010




Sources: BEA, Eurostat and OECD

**External Trade: Malaysia**
June 2009–August 2010




Source: Department of Statistics, Malaysia

**Inflation Rates: US, Euro Zone & Japan**
(% price change from a year earlier)




Sources: IMF and *Economist* (1 November 2010)

**Inflation Rate: China, Hong Kong & South Korea**
(% price change from a year earlier)




Sources: IMF and *Economist* (1 November 2010)

**Inflation Rate: Selected ASEAN Countries**
(% price change from a year earlier)




Sources: IMF and *Economist* (1 November 2010)

# អត្រាប្តូរប្រាក់ និង ស្ថានភាពថ្លៃទំនិញលើទីផ្សារអន្តរជាតិ

# Exchange Rates and Commodity Prices in World Markets

## KRW & HKD per USD
August 2009–October 2010




Source: Federal Reserve Bank of New York

## EUR & JPY per USD
August 2009–October 2010




Source: Federal Reserve Bank of New York

## THB & SGD per USD
August 2009–October 2010




Source: Federal Reserve Bank of New York

## Rice: International Prices Index & Export Prices
August 2009–October 2010




Sources: Osiriz/InfoArroz
*International Price Index of Osiriz/InfoArroz

## Prices: Soybeans, Maize & Rubber
August 2009–October 2010




Source: Food and Agriculture Organisation

## Prices: Crude Oil, Gasoline & Diesel
June 2009–August 2010




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

## ព័ត៌មានសេដ្ឋកិច្ចសំខាន់ៗ

***វិភាគព័ត៌មាន ៖ ទីផ្សារផ្តល់ផលកម្រៃច្រើនរបស់អាស៊ាន ជំរុញឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី***

ទីផ្សារផ្តល់ផលកម្រៃច្រើនរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) បានជំរុញឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ។ អាស៊ានដែលមានប្រទេសសមាជិកចំនួន ១០ គឺជាទីផ្សារកំពុងរីកលូតលាស់យ៉ាងលឿនបំផុតមួយក្នុងសាកលលោក ដោយមានប្រជាជនសរុបជិតដល់ ៥៩០លាននាក់ និង ផលិតផលក្នុងស្រុកសរុប (ផសស) ប្រមាណ ១,៤៦លានលានដុល្លារអាមេរិក ។

នៅថ្ងៃទី១ មករា ២០១០ FTA ចំនួន ៤ បានចូលជាធរមាន គឺមាន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលហ្សេឡង់ (AANZFTA) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េខាងត្បូង (KAFTA) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន និង តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ។

ដោយហេតុថា នៅមានអតុល្យភាពរវាងបណ្តាប្រទេសសមាជិកអាស៊ាន ដោយសារប្រទេសខ្លះមានកំណើនលឿនជាងប្រទេសខ្លះទៀត ដូច្នេះប្រទេសជាដៃគូ FTA ត្រូវរង់ចាំមួយរយៈ ហើយជួនកាលត្រូវផ្តល់ជំនួយទៅសមាគមនេះផង ដើម្បីឲ្យរៀបចំខ្លួន ។ ឧទាហរណ៍ ប្រទេសអូស្ត្រាលី នឹងផ្តល់ទឹកប្រាក់ ១៩,៧លានដុល្លារក្នុងរយៈពេល ៥ឆ្នាំ ដើម្បីគាំទ្រប្រទេសអាស៊ានក្នុងការអនុវត្តកិច្ចព្រមព្រៀង ។

នៅឆ្នាំ២០០៧ សហភាពអឺរ៉ុប (EU) និងអាស៊ាន បានព្រមព្រៀងចាប់ផ្តើមការចរចាអំពី FTA អាស៊ាន-EU ប៉ុន្តែការចរចានេះបានផ្អាកនៅខែមីនា ២០០៩ ដោយសារបញ្ហាបច្ចេកទេសមួយចំនួន ។ បន្ទាប់មក EU ក៏ប្រឹងប្រែងធ្វើ FTA ទ្វេភាគី ជាមួយប្រទេសអាស៊ានមួយចំនួន ។ Walter Van Hattum លេខាធិការទី១ នៃ ផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្ម នៃគណៈប្រតិភូ EU ប្រចាំប្រទេសឥណ្ឌូនេស៊ី បានលើកថា EU មានមហិច្ឆតាក្នុងការបង្កើតឱកាសថ្មីៗនៅអាស៊ាន ដោយធ្វើ FTA ទ្វេភាគីជាមួយប្រទេសដែលមានមហិច្ឆតាដូចគ្នា និងមានសមត្ថភាព ។

នៅពេលសេដ្ឋកិច្ចកាន់តែមានលក្ខណៈសាកលភាវូបនីយកម្ម តម្រូវការនូវវិនិយោគ និងពាណិជ្ជកម្មសេរី ក៏ត្រូវកើនឡើងដោយជៀសមិនផុត ។ យោងតាមសំដីរបស់ Elly Lawson ទីប្រឹក្សាសេដ្ឋកិច្ចនៃស្ថានទូតអូស្ត្រាលីប្រចាំប្រទេសឥណ្ឌូនេស៊ី AANZFTA បានត្រួសត្រាយផ្លូវសម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចកាន់តែស៊ីជម្រៅរវាង អាស៊ាន អូស្ត្រាលី និង នូវែលហ្សេឡង់ ។ Lawson បានបន្ថែមថា វាផ្តល់នូវភាពច្បាស់លាស់ និងតម្លាភាពកាន់តែច្រើនសម្រាប់អ្នកវិនិយោគ តាមរយៈរបបនៃការការពារវិនិយោគ ។

Yang Sooyang នាយករងនៃនាយកដ្ឋាន FTA នៃក្រសួងអប់រំរបស់កូរ៉េខាងត្បូង បាននិយាយថា KAFTA បានជួយបង្កើនតម្លាភាពវិធានការវិនិយោគ និងលើកកម្ពស់ការការពារវិនិយោគ ។ សម្រាប់កូរ៉េខាងត្បូង អាស៊ានគឺជាដៃគូសេដ្ឋកិច្ចដ៏សំខាន់បំផុតមួយ និងជាដៃគូពាណិជ្ជកម្មធំលំដាប់ទីបី ក្នុងឆ្នាំ២០០៩ ហើយពាណិជ្ជកម្មរវាងដៃគូទាំងពីរនេះមានតម្លៃដល់ទៅ ៧៥ពាន់លានដុល្លារអាមេរិក ។ អាស៊ានជាអ្នកវិនិយោគធំលំដាប់ទីប្រាំនៅកូរ៉េខាងត្បូង ដោយមានវិនិយោគបូកត្រួតតម្លៃ (cumulative investment) ១៣ពាន់លានដុល្លារសហរដ្ឋអាមេរិក ឬ ៨,៣% នៃវិនិយោគផ្ទាល់ពីបរទេសសរុបនៅប្រទេសនោះ ។ សម្រាប់អូស្ត្រាលី អាស៊ានគឺជាដៃគូពាណិជ្ជកម្មធំលំដាប់ទីបី បន្ទាប់ពីចិន និង សហភាពអឺរ៉ុប ដោយមានទំហំពាណិជ្ជកម្មដល់ប្រមាណ ៨៧ពាន់លានដុល្លារអូស្ត្រាលី នៅក្នុងឆ្នាំ២០០៩ ។ (ប្រភព ៖ Xinhua, ថ្ងៃទី១៩ ខែវិច្ឆិកា)

## Economic News Highlights:

***News Analysis: ASEAN's lucrative market triggers FTA***

The Association of South-East Asian Nations' lucrative market has prompted the conclusion of a series of free trade agreements (FTA). The 10-member ASEAN is one of the world's fastest growing markets, with a combined population of almost 590 million and GDP of USD1.46 trillion.

On 1 January 2010, four FTA came into effect: the ASEAN-Australia-New Zealand Free Trade Agreement (AANZFTA), South Korea-ASEAN Free Trade Area (KAFTA), ASEAN-China Free Trade Area and ASEAN-India Free Trade Area.

However, as there is imbalance among ASEAN member countries, with some countries growing faster than others, the FTA partners need to wait, even to aid the bloc to prepare itself. For example, Australia will provide about USD19.7 million over five years to assist ASEAN countries to implement the agreement.

In 2007, the European Union and ASEAN agreed to start EU-ASEAN FTA negotiations. However, they halted the negotiations in March 2009 due to several technical problems. The EU then tried to reach bilateral FTA with several ASEAN countries. Walter Van Hattum, First Secretary of the Economic and Trade Section in the EU delegation to Indonesia, said that the EU has ambitions to create new opportunities in ASEAN by embracing bilateral FTA with countries that share the ambition and are capable.

As economies become increasingly globalised, demand for free trade and investment is unavoidably rising. According to Elly Lawson, economic counsellor of the Australian embassy in Indonesia, the AANZFTA paves the way for deeper economic integration between the bloc, Australia and New Zealand. "It provides greater transparency and certainty for investors through a regime of investment protection", said Lawson.

Yang Sooyoung, assistant director of the FTA Division of South Korea's Ministry of Knowledge, said that the KAFTA has improved transparency of investment measures and enhanced protection of investments. For South Korea, ASEAN is one of the most important economic partners and the third largest trading partner in 2009 with trade between them worth USD75 billion. ASEAN is the fifth largest investor in South Korea, with cumulative ASEAN investment worth USD13 billion or 8.3 percent of total foreign direct investment in the country. For Australia, ASEAN is the third largest trading partner, after China and the European Union, with trade volume of AUD87 billion in 2009.

(Source: Xinhua, 19 November)

***Links to other economic news:***

1. "News Analysis: ASEAN commits joint efforts in tackling non-traditional security threats" (http://news.xinhuanet.com/english2010/world/2010-10/30/c_13583560.htm)
2. "U.S. engagement with Southeast Asia part of Asia strategy: officials" (http://news.xinhuanet.com/english2010/world/2010-10/29/c_13580596.htm)